ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ៥១/០៩ - យ៉ុង វ៉ា ទី១ ទី២**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១-ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន យ៉ុង វ៉ា ទី១ និង ទី២**

អាសយដ្ឋាន : ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ :០១២ ៥១០ ៥៦៦ ឬ ០១២ ៨៩៥ ៣៧០ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- Ms IRIS TENG | ប្រធានផ្នែកធនធានមនុស្ស ប្រចាំនៅប្រទេសសិង្ហបុរី |
| ២- Ms Jane Lee | ប្រធានផ្នែកធនធានមនុស្ស ប្រចាំនៅប្រទេសកម្ពុជា |
| ៣- លោក សោម អ៊ុយពិសី | រដ្ឋបាល |
| ៤- លោកស្រី ឈិន ជូហ្វាង | រដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

**ក-ឈ្មោះ : សហព័ន្ធសហជីព-សហជីពកម្មករប្រជាធិបតេយ្យខ្មែរ ប្រចាំរោងចក្រ យ៉ុង វ៉ា (EUKDW)**

អាសយដ្ឋាន : ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

ទូរស័ព្ទ : ០១៦ ២១១ ៤៣៣ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត :

១- លោក រឹម បូរ៉ា ប្រធានសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរ

២- លោក ជឹម បូរ៉ា អនុប្រធានសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យខ្មែរ

៣- លោក ស៊ិន សុផាត អនុប្រធានសហជីព (FUKDW) យ៉ុងវ៉ា ២

៤- លោកស្រី យាន ណេងអ៊ិន ប្រធានសហជីព (FUKDW) យ៉ុងវ៉ា ២

៥- លោកស្រី ជឿន ស្រីមុំ ប្រធានដេរ យ៉ុង វ៉ា ទី២

**ខ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ កម្ពុជា ប្រចាំរោងចក្រ យ៉ុង វ៉ា**

អាសយដ្ឋាន : ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១២ ៩៨៨ ៦២៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី មាស វណ្ណី មន្ត្រីដោះស្រាយវិវាទសហព័ន្ធសហជីព CCAWDU

២- លោកស្រី សុខ ផល្លា ប្រធានសហជីព CCAWDU ប្រចាំរោងចក្រ យ៉ុង វ៉ា ទី២

៣- លោក មុំ សុវណ្ណ ប្រធានសហជីព CCAWDU ប្រចាំរោងចក្រ យ៉ុង វ៉ា ទី១

៤- លោកស្រី ចាន់ ដានី អនុប្រធានសហជីព CCAWDU ប្រចាំរោងចក្រ យ៉ុង វ៉ា ២

៥- លោកស្រី កែវ សម្ផស្ស លេខាធិការសហជីព CCAWDU ប្រចាំរោងចក្រ យ៉ុង វ៉ា២

៦- លោកស្រី កេន ដួងម៉ាលី ប្រធានក្រុម

៧- លោកស្រី មែន សុភាព ប្រធានក្រុម

៨- លោក កុល សារឿន ប្រធានក្រុម

**គ-ឈ្មោះ : សហព័ន្ធសហជីពកម្មករកម្ពុជា -សហជីពកម្មករនិយោជិត ប្រចាំរោងចក្រ យ៉ុង វ៉ា**

អាសយដ្ឋាន : ផ្ទះលេខ ៣០ សេ ផ្លូវលេខ ៣៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ភ្នំពេញ

លេខទូរស័ព្ទ : ០១១ ៦៨៥ ៨២៦ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សេង ម៉េងហុង មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា

២- លោក កែវ សុទ្ធា ប្រធានសហជីពកម្មករនិយោជិត ប្រចាំរោងចក្រ យ៉ុង វ៉ា ៤

៣- លោក ភិន ធូក ប្រធានសហជីពកម្មករនិយោជិត ប្រចាំរោងចក្រ យ៉ុង វ៉ា ២

៤- លោកស្រី អ៊ុំ សុធា ប្រធានសហជីពកម្មករនិយោជិត ប្រចាំរោងចក្រ យ៉ុង វ៉ា ១

THE ARBITRATION COUNCIL

៥- លោក ឌុច ឌីចាន់ការ អនុប្រធានសហជីពកម្មករនិយោជិត ប្រចាំរោងចក្រ យ៉ុងវ៉ា ៣

៦- លោកស្រី សួន សុខា អនុប្រធានសហជីពកម្មករនិយោជិតប្រចាំរោងចក្រ យ៉ុងវ៉ា ១

៧- លោក សេង វេច្ចនា លេខាធិការសហជីពកម្មករនិយោជិតប្រចាំរោងចក្រ យ៉ុងវ៉ា ២

៨- លោកស្រី ឈក ចាន់ណាន់ លេខាធិការសហជីពកម្មករនិយោជិត ប្រចាំរោងចក្រ យ៉ុងវ៉ា១

៩- លោក មាស វណ្ណី ទីប្រឹក្សាសហជីពកម្មករនិយោជិត

**ឃ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពប្រជាធិបតេយ្យជឿនលឿន ប្រចាំរោងចក្រ យ៉ុង វ៉ា**

អាសយដ្ឋាន : ផ្ទះលេខ ១៩៧ ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៤១៧ ៣៩៧ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី ជា ស្រីនាង ប្រធានសហជីពប្រជាធិបតេយ្យជឿនលឿន ប្រចាំរោងចក្រ

២- លោកស្រី មាស សុភាព អនុប្រធានសហជីពប្រជាធិបតេយ្យជឿនលឿន ប្រចាំរោងចក្រ

៣- លោកស្រី ហេង ចំរើន លេខាធិការសហជីពប្រជាធិបតេយ្យជឿនលឿន ប្រចាំរោងចក្រ

**ង-ឈ្មោះ : សហព័ន្ធសហជីព-សហជីពសេរីកម្មករ ប្រចាំរោងចក្រ យ៉ុង វ៉ា**

អាសយដ្ឋាន : ផ្ទះលេខ ២៨ បេ ផ្លូវលេខ ២២២ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨៣៩ ៥១៥ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី សូត្រ ចន្ធូ មន្ត្រីសហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

២- លោកស្រី ឆាយ សុខឡាយ ប្រធានសហជីពសេរីកម្មករ ប្រចាំរោងចក្រ

៣- លោក អ៊ឹម ពិសី អនុប្រធានសហជីពសេរីកម្មករ ប្រចាំរោងចក្រ

៤- លោក ប៉ែន សារិទ្ធ លេខាធិការសហជីពសេរីកម្មករ ប្រចាំរោងចក្រ

**ច-ឈ្មោះ : សហព័ន្ធសហជីព-សហជីពខ្មែរ ប្រចាំរោងចក្រ យ៉ុង វ៉ា**

អាសយដ្ឋាន : ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្ដាល

លេខទូរស័ព្ទ : ០១២ ៦៥៨ ១២៩ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ម៉ុម ធន មន្ត្រីដោះស្រាយវិវាទ សហព័ន្ធសហជីពខ្មែរ

២- លោក ជា សុផា មន្ត្រីដោះស្រាយវិវាទ សហព័ន្ធសហជីពខ្មែរ

THE ARBITRATION COUNCIL

៣- លោកស្រី ឡុង សុម៉ាលី លេខាសហជីពខ្មែរ ប្រចាំរោងចក្រ យ៉ុង វ៉ាទី២

**ឆ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពយុវជនខ្មែរ ប្រចាំរោងចក្រ យ៉ុង វ៉ា**

អាសយដ្ឋាន : ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្ដាល

លេខទូរស័ព្ទ : ០១២ ៩០៦ ៨១១ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករទាមទាររយៈពេលព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៩ (០២ខែ) សូមឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួល ១០០ ភាគរយ។ ក្រុមហ៊ុនមិនឯកភាព គឺ អនុវត្តតាមច្បាប់ស្ដីពីការងារ ត្រង់មាត្រ ៧១ និងមាត្រា ៧២ ហើយនឹងអនុវត្តតាមលិខិតសំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ និងលិខិតស្ដីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត លេខ ១៣០-១៣១ កប/កណ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ (ការព្យួរកិច្ចសន្យានេះ ចាប់ផ្ដើមពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ រហូត ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩)។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជា ឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្ដីពីការតែងតាំង សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នា ឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជា លេខ ១៣៣/០៩ កប/កណ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨។

THE ARBITRATION COUNCIL

## សវនាការ និង សន្ទមនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៩ (វេលាម៉ោង ០៨:០០នាទី ដល់ម៉ោង ១២:០០នាទី) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួម ចំនួន ០១ ចំណុច ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតនៅក្រុមហ៊ុន យ៉ុង វ៉ា ទី១ ទី២ ដោយយោងតាមលិខិតលេខ ១៣០-១៣១/០៩ កប/កណ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលមិនសះជានឹងគ្នា ចំនួន ០១ ចំណុច លើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជា ចំនួន ០១ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត ប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក។

ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០១ ចំណុចនេះ បន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុន លេខ ៩៨១ ពណ.នគក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ១៩៩៨។

២- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូ.អិលធីឌី ទី២ លេខ ០០៨/០៦ ក.ប.វ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦។

THE ARBITRATION COUNCIL

៣- អនុស្សារណៈ និងលក្ខន្តិកៈ របស់ក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូ.លីមីធីឌ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២ ។

៤- តារាង (Yung Wah Order Record) ។

៥- លិខិតរបស់ក្រុមហ៊ុន លេខ ៥២៤/០៩ យវ គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីសំណើសុំចុះអធិការកិច្ចមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជួយចុះពិនិត្យនៅរោងចក្រ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូ.អិលធីឌី ទី១ និងជួយវាយតម្លៃ ការពិត និងសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ផ្នែកមួយចំនួនដែលមានសរុប ៧៩២ នាក់ រយៈពេលពីរខែជាបណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩។

៦- លិខិតរបស់ក្រុមហ៊ុន លេខ ៤៩៣/០៩ យវ គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីសំណើសុំចុះអធិការកិច្ច មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជួយចុះពិនិត្យនៅរោងចក្រ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូ.អិលធីឌី ទី២ និងជួយវាយតម្លៃការពិត និងសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ផ្នែកមួយចំនួនដែលមានសរុប ២១៨០ នាក់ រយៈពេលពីរខែជាបណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩។

៧- លិខិតលេខ ១៣០/០៩ កប/កណ របស់ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាសស្ទ្រៀល (ខេមបូឌា)ខូ.អិលធីឌី ទី២ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។

៨- លិខិតលេខ ១៣១/០៩ កប/កណ របស់ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាសស្ទ្រៀល (ខេមបូឌា) ខូ.អិលធីឌី ទី១ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។

៩- តារាងបណ្តែតផ្នែក និងចំនួនកម្មករនិយោជិត ដែលសុំព្យួរការងារ ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ មានអាគារទី២ អាគារទី៣ អាគារទី៤ សរុបចំនួន ២១៨០ នាក់ លេខ ៤៩៤/០៩ យវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩។

១០- តារាងបណ្តែតផ្នែក និងចំនួនកម្មករនិយោជិត ដែលសុំព្យួរការងារ ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ មានអាគារទី២ អាគារទី៣ អាគារទី៤ សរុបចំនួន ៧៩២ នាក់ លេខ ៥២៥/០៩ យវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩។

១១- បញ្ជីឈ្មោះកម្មករនិយោជិតដែលត្រូវបានព្យួរការងារ រយៈពេល ០២ ខែ ដោយយោងតាមមាត្រា ៧១ នៃច្បាប់ស្តីពីការងារ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ ។

THE ARBITRATION COUNCIL



Rhea

១២- កំណត់ហេតុដោះស្រាយវិវាទការងាររួម រោងចក្រកាត់ដេរសំលៀកបំពាក់ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។

១៣- លិខិតផ្ទេរសិទ្ធិជូន លោកស្រី IRIS TENG ជាប្រធានគ្រប់គ្រងធនធានមនុស្ស ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

**-សហជីពសេរីកម្មករ**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសេរីកម្មករ នៃរោងចក្រកាត់ដេរ យ៉ុង វ៉ា ២ លេខ ១៤០៩ កប/វក. ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨។

**-សហជីពប្រជាធិបតេយ្យជឿនលឿន**

១- លិខិតបញ្ជាក់របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជិកា របស់សហជីព កម្មករកាត់ដេរជឿនលឿន នៃរោងចក្រ យ៉ុង វ៉ា ទី២ លេខ ០៥៦/០៩ កប ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។

**-សហជីពកម្មករនិយោជិត**

១- លិខិតបញ្ជាក់របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជិកា របស់សហជីព កម្មករនិយោជិតរោងចក្រ យ៉ុង វ៉ា ទី២ លេខ ១៧០ កប ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៧។

២- លិខិតបញ្ជាក់របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជិកា របស់សហជីព កម្មករនិយោជិតរោងចក្រ យ៉ុង វ៉ា ទី១ លេខ ១៦៦ កប ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៧។

៣- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥១០ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

៤- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥០៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

៥- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥១៥ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

៦- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥១៤ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

៧- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥១៣ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

៨- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥១២ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

៩- ប័ណ្ណបញ្ជូនទំនិញ លេខ ០០៥៥១១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

**-សហជីពខ្មែរ**

១- លិខិតបញ្ជាក់របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបទៅ អ្នកស្រីប្រធានសហជីពខ្មែរ នៃ រោងចក្រ យ៉ុង វ៉ា លេខ ១០០ កប/អក/វក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

THE ARBITRATION COUNCIL

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម រោងចក្រកាត់ដេរសំលៀកបំពាក់ យ៉ុង វ៉ា អ៊ិនដាស្ត្រៀល(ខេមបូឌា) ខូអិលធីឌី លេខ ១៣៣/០៩ កប/កណ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួម រោងចក្រកាត់ដេរសំលៀកបំពាក យ៉ុង វ៉ា អ៊ិនដាស្ត្រៀល (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ២១៧ កប/អក/លកអ. ចុះថ្ងៃទី០៣ ខែ មេសា ឆ្នាំ២០០៩ ។

២- លិខិតអញ្ជើញភាគីក្រុមហ៊ុនចូលរួមសវនាការលេខ ២១៦ កប/អក/ លកអ. ចុះថ្ងៃទី០៣ ខែ មេសា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន យ៉ុង វ៉ា ចាប់បើកដំណើរការនៅឆ្នាំ ១៩៩៨។ បច្ចុប្បន្ននេះ មានជួលកម្មករនិយោជិតសរុបចំនួនប្រមាណជាង ៥០០០ នាក់។ ក្នុងនោះ មានកម្មករនិយោជិតចំនួន ២៩៧២ នាក់ ដែលក្រុមហ៊ុនបានព្យួរកិច្ចសន្យាការងារ រយៈពេល ០២ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩។
- នៅក្នុងក្រុមហ៊ុនមានសហជីព ចំនួន ៧ គឺ ១. សហជីពយុវជនខ្មែរ ២. សហជីពសេរីកម្មករ ៣. សហជីពកម្មករនិយោជិត ៤. សហជីពខ្មែរ ៥. សហជីពប្រជាធិបតេយ្យជឿនលឿន ៦. សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ និង ៧. សហជីពប្រជាធិបតេយ្យខ្មែរ ដែលជាភាគី ដើមបណ្តឹងក្នុងសំណុំរឿងនេះ។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ មានភាពតំណាងបំផុត។

**ចំណុចវិវាទ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ក្នុងរយៈពេល០២ខែ នៃការព្យួរកិច្ចសន្យាកម្មករនិយោជិត ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩**

THE ARBITRATION COUNCIL

- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ក្រុមហ៊ុនបានធ្វើសំណើស្នើសុំអធិការកិច្ចមន្ទីរការងារ និងបណ្តុះបណ្តាល ខេត្តកណ្តាល ជួយចុះពិនិត្យនៅរោងចក្រ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូអិលធីឌី ទី១ និងជួយវាយតម្លៃការពិត និងសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ផ្នែកមួយចំនួន ដែលមានកម្មករសរុប **៧៩២ នាក់** រយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩។
- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ក្រុមហ៊ុនបានធ្វើសំណើស្នើសុំអធិការកិច្ចមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជួយចុះពិនិត្យនៅរោងចក្រ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូអិលធីឌី ទី២ និងជួយវាយតម្លៃការពិត និងសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ផ្នែកមួយចំនួន ដែលមានកម្មករសរុប **២១៨០ នាក់** រយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩។
- នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចេញលិខិតឆ្លើយតបនឹងការស្នើសុំព្យួរកិច្ចការងារកម្មករនិយោជិតចំនួន ៧៩២ នាក់ នៅរោងចក្រ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូអិលធីឌី ទី១ តាមរយៈលិខិតលេខ ១៣១/០៩ កប/កណ។
- នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចេញលិខិតឆ្លើយតបនឹងការស្នើសុំព្យួរកិច្ចការងារកម្មករនិយោជិតចំនួន ២១៨០ នាក់ នៅរោងចក្រ យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូអិលធីឌី ទី២ តាមរយៈលិខិតលេខ ១៣០/០៩ កប/កណ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ដែលក្រុមហ៊ុនបានធ្វើសំណើសុំទៅអធិការកិច្ចមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាលនោះ គឺក្រុមហ៊ុនមិនបានជូនដំណឹងដល់កម្មករនិយោជិតទេ។
- នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩ មន្ទីការងារបានចុះធ្វើអធិការកិច្ច។ បន្ទាប់ពីមន្ទីរការងារធ្វើអធិការកិច្ចរួចមក ក្រុមហ៊ុនបានកោះប្រជុំជាមួយកម្មករនិយោជិត ដោយមិនទទួលបានលទ្ធផលទេ ហើយកិច្ចប្រជុំត្រូវលើកទៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩។ ភាគីកម្មករនិយោជិតបានជំទាស់ថា ពួកគាត់មិនបានដឹងហើយក៏មិនបានចូលរួមប្រជុំនេះដែរ។
- នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ក្រុមហ៊ុនបានប្រជុំជាមួយកម្មករនិយោជិត ប៉ុន្តែនៅតែមិនទទួលបានលទ្ធផលដដែល។ ភាគីកម្មករនិយោជិតបានឯកភាពថា ពួកគាត់បានដឹង ព្រមទាំងមានតំណាងកម្មករនិយោជិតខ្លះចូលរួមប្រជុំផងដែរ។
- នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ ខេត្តកណ្តាល បានចុះធ្វើការផ្សះផ្សា និងដោះស្រាយការទាមទារដែលពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យានេះ ជាមួយក្រុមហ៊ុន និងកម្មករនិយោជិត ប៉ុន្តែមិនទទួលបានលទ្ធផលដដែល ពីព្រោះកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់

ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងរយៈពេល ០២ ខែ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតនេះ ហើយនៅថ្ងៃដដែលនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ក៏បានបញ្ជូនរបាយការណ៍មិនសះជានេះ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល។

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ក្រុមហ៊ុននៅមានការងារឱ្យកម្មករនិយោជិតធ្វើ ពីព្រោះចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ មក ក្រុមហ៊ុនបានដឹកក្រណាត់ចេញទៅឱ្យរោងចក្រផ្សេងទៀត។ ភាគីក្រុមហ៊ុនបានជំទាស់ ដោយបញ្ជាក់ថា ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ក្រុមហ៊ុនមិនមានដឹកក្រណាត់ចេញទៅក្រៅទេ។ ប៉ុន្តែ បើមានដឹកក្រណាត់ចេញ គឺមានតិចតួចប៉ុណ្ណោះ ពីព្រោះក្រុមហ៊ុននៅជាប់កិច្ចសន្យាដែលនៅសេសសល់ ហើយសព្វថ្ងៃនេះ មិនមានទៀតទេ។ ចំណែកឯឃ្លាំងស្តុកក្រណាត់នៅ យ៉ុង វ៉ាទី២ គឺក្រុមហ៊ុនបញ្ជូនក្រណាត់ពី អាគារថ្មី យ៉ុង វ៉ាទី២ ទៅអាគារចាស់ យ៉ុង វ៉ាទី១។
- ភាគីកម្មករនិយោជិតបានលើកហេតុផលថា កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងរយៈពេល ០២ ខែ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតនេះ ពីព្រោះ :
  - *ក្រុមហ៊ុនជូនដំណឹងទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ប៉ុន្តែមិនបានជូនដំណឹងដល់កម្មករនិយោជិត។*
  - *ក្រុមហ៊ុនមិនបានបញ្ជាក់អំពីហេតុផល នៃការព្យួរកិច្ចសន្យាការងារនេះ ដល់កម្មករនិយោជិតទេ ហើយក្រុមហ៊ុនព្យួរកិច្ចសន្យាការងារនេះ មានលក្ខណៈបន្ទាន់ ។*
  - *នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ក្រុមហ៊ុនបានបិទទ្វាររោងចក្រ មិនឱ្យកម្មករនិយោជិតចូល គឺកម្មករនិយោជិតនៅក្រៅរោងចក្រទាំងអស់គ្នា។*
  - *មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមែនជាអធិការកិច្ចការងារទេ ហើយលិខិតរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការព្យួរកិច្ចសន្យាការងារនេះ ក៏មិនមានខ្លឹមសារដែលចែងថា អនុញ្ញាតឱ្យក្រុមហ៊ុនព្យួរកិច្ចសន្យាការងារ តាមសំណើសុំរបស់ក្រុមហ៊ុនទេ។*
- ភាគីក្រុមហ៊ុនបានលើកហេតុផលថា ក្រុមហ៊ុនបានអនុវត្តការព្យួរកិច្ចសន្យាការងារ តាមមាត្រា ៧១ និង មាត្រា ៧២ នៃច្បាប់ស្តីពីការងារ។ ហេតុនេះហើយ ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងរយៈពេល ០២ ខែ នៃការព្យួរកិច្ចសន្យាការងារនេះ តាមការទាមទាររបស់កម្មករនិយោជិតបានទេ។

**ហេតុផលនៃសេចក្តីសម្រេច**

**កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងរយៈពេល ០២ ខែ នៃការព្យួរកិច្ចសន្យាកម្មករនិយោជិត ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩**

THE ARBITRATION COUNCIL

ពាក់ព័ន្ធតាមការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើក្រុមហ៊ុនបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុប ចំនួន ២៩៧២ នាក់ ដែលមានរយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ គឺជាការអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដែរឬទេ?

ការព្យួរកិច្ចសន្យាការងារ ត្រូវធ្វើឡើងតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ដូចមានចែងក្នុងមាត្រា ៧១ កថាខណ្ឌ ទី ១១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ដោយមូលហេតុ ដូចខាងក្រោម :

*"ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពីពីរខែ ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ ។"*

មាត្រា ៧២ ចំណុចទី ១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា *" ការព្យួរកិច្ចសន្យាការងារ នាំឱ្យប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗ នៃកិច្ចសន្យាការងារ ពោលគឺ កាតព្វកិច្ចដែលកម្មករនិយោជិត ត្រូវធ្វើការឱ្យនិយោជក និង កាតព្វកិច្ចដែលនិយោជក ត្រូវផ្តល់ប្រាក់ឈ្នួល ដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត "* ។

យោងតាមមាត្រា ៧១ កថាខណ្ឌទី១១ នៃច្បាប់ស្តីពីការងារខាងលើនេះ ទាក់ទងនឹងការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនត្រូវមានការជូនដំណឹង ទៅអធិការកិច្ចការងារ និងមានការពិនិត្យ និងបញ្ជាក់ពីអធិការកិច្ចការងារជុំវិញបញ្ហាព្យួរកិច្ចសន្យាការងារនេះ។ មានន័យថា អធិការកិច្ចការងារមានភារកិច្ចចុះត្រួតពិនិត្យ និងផ្តល់យោបល់ជុំវិញសកម្មភាពព្យួរការងាររបស់ក្រុមហ៊ុនថា ពិតជាអនុលោមទៅតាមភាពជាក់ស្តែងនៃស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ចពិតប្រាកដមែន។ (សូមមើលសេចក្តីបង្គាប់លេខ *២៧/០៨-អាក ឃីត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦ និងលេខ ១៣៦/០៨- ស៊ូភើឌីច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទ ទី២)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ច្បាប់ស្តីពីការងារ បានផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុន ក្នុងការព្យួរកិច្ចសន្យាការងារ ប៉ុន្តែការព្យួរកិច្ចសន្យាការងារនេះ និយោជកត្រូវធ្វើបែបបទជូនដំណឹងទៅអធិការកិច្ចការងារអំពីមូលហេតុ ដែលបណ្តាលក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិត និងរយៈពេលនៃការព្យួរការងារនោះ។

ប្រសិនបើ ក្រុមហ៊ុនបានធ្វើបែបបទព្យួរការងារត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដោយការព្យួរការងារនោះ ត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យពីអធិការកិច្ចការងារនោះ ក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតឡើយ (សូមមើលមាត្រា ៧២ (១) នៃច្បាប់ស្តីពីការងារ) ។ ប៉ុន្តែ ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ដល់កម្មករនិយោជិត ទោះបីជាពុំមានការងារឱ្យកម្មករធ្វើការក៏ដោយ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *២១/០៣-ឡូយ៉ាល់ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៨ លេខ០១/០៤-ញូវ ភាញ់ លេខ៤៦/០៤-អេម អេន អេ ហេតុផលនៃសេចក្តីសម្រេច ចំណុច*

*វិវាទទី ១ លេខ ៧៤/០៧-គួបលអាប៉ារ៉ែល ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ លេខ ២៨/០៨-បញ្ញជិស ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និង២ លេខ ៥៣/០៨-យ៉ុង វ៉ា ទី១ ហេតុផលនៃ សេចក្តីសម្រេច ចំណុចវិវាទទី១ និង លេខ ១៣៦/០៨-ស៊ូភើថិច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២* ) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ក្រុមហ៊ុន យ៉ុង វ៉ា បានធ្វើបែបបទស្នើសុំអធិការកិច្ចមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជួយចុះពិនិត្យ នៅរោងចក្រ និងជួយវាយតម្លៃការពិត និងសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតផ្នែកមួយចំនួន នៅយ៉ុង វ៉ាទី១ ដែលមានកម្មករនិយោជិត **ចំនួន ៧៩២ នាក់** និង យ៉ុង វ៉ាទី២ ដែលមានកម្មករនិយោជិត **ចំនួន ២១៨០ នាក់** សម្រាប់រយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ ដោយមូលហេតុ ក្រុមហ៊ុនមានការបញ្ជាទិញថយចុះ ( មានចំនួនតិច) ធ្វើឱ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចេញលិខិតឆ្លើយតបនឹងការស្នើសុំព្យួរកិច្ចសន្យាការងាររបស់ លោកនាយកក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត នៅ យ៉ុង វ៉ាទី១ ដែលមានកម្មករនិយោជិត **ចំនួន ៧៩២ នាក់** និង យ៉ុង វ៉ាទី២ ដែលមានកម្មករនិយោជិត **ចំនួន ២១៨០ នាក់** សម្រាប់រយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ ។

ដូច្នេះ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ត្រឹមត្រូវតាមច្បាប់ស្តីពីការងារហើយ ។

ប៉ុន្តែ ទាក់ទងនឹងការលើកឡើងរបស់កម្មករនិយោជិតដែលថា និយោជកមិនបានធ្វើការជូនដំណឹងដល់កម្មករនិយោជិតអំពីការព្យួរនេះ។ នៅក្នុងសំរឿងលេខ ៤៦/០៥- អូ សេ អង់ ប្លាមិន ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ក្នុងច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ក៏មិនមានមាត្រាណាមួយ ដែលចែងអំពីការតម្រូវឱ្យភាគីក្រុមហ៊ុនជូនដំណឹងដល់កម្មករនិយោជិត នៅក្នុងរយៈពេលប៉ុន្មានថ្ងៃ ឬម៉ោងនោះទេ ..... ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចជូនដំណឹងដល់កម្មករនិយោជិតអំពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន គឺនៅពេលដែលក្រុមហ៊ុនទទួលបានលិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនត្រូវបិទផ្សាយភ្លាម ឬក៏ឱ្យបានឆាប់តាមការដែលអាចធ្វើទៅបាន ។*"

លើសពីនេះទៀត ភាគីកម្មករនិយោជិតបានជំទាស់ថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល មិនមែនជាអធិការកិច្ចការងារទេ ហើយនៅក្នុងលិខិតនោះ គឺមិនមានខ្លឹមសារដែលចែងថា បានអនុញ្ញាតឱ្យក្រុមហ៊ុន ព្យួរកិច្ចសន្យាការងារ តាមសំណើសុំរបស់ក្រុមហ៊ុនទេ។

ពាក់ព័ន្ធទៅនឹងលិខិតឆ្លើយតបរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងាររបស់និយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា នៅក្នុងលិខិតឆ្លើយតប របស់

ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត របស់លោកនាយកក្រុមហ៊ុន យ៉ុង វ៉ា ទី១ និងទី២ នេះ គឺមានទម្រង់ និងខ្លឹមសារដូចគ្នា ទៅនឹងលិខិតឆ្លើយតប របស់ប្រធានមន្ទីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង និងរាជធានីភ្នំពេញ ជាទូទៅ គឺមិនមានខ្លឹមសារ ដែលថែងថា បានអនុញ្ញាតឱ្យក្រុមហ៊ុនព្យួរកិច្ចសន្យាការងារ តាមសំណើសុំរបស់ក្រុមហ៊ុនទេ នៅក្នុងសំណុំរឿង មុនៗ ។

លើសពីនេះទៀត ទាក់ទងនឹងការចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិត នៅពេលក្រុមហ៊ុនជួបវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកត់សំគាល់ឃើញថា ការ អនុវត្តកន្លងមក បើសិនក្រុមហ៊ុនមានទីតាំងនៅតាមបណ្តាខេត្តនានា ជាទូទៅមានតែមន្ទីរការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ នៅតាមខេត្តនោះទេ ជាអ្នកចេញលិខិត ហើយបើក្រុមហ៊ុនមានទីតាំងនៅរាជធានីភ្នំពេញ គឺនាយកដ្ឋាន អធិការកិច្ចការងារ ជាអ្នកចេញលិខិត ។

ម្យ៉ាងវិញទៀត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *"ការត្រួតពិនិត្យ របស់អធិការកិច្ចការងារ គឺជៀសវាងកុំឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរ ពីព្រោះការព្យួរកិច្ចសន្យាការងារ គឺជាការប៉ះ ពាល់មួយដ៏ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ និងអត្ថប្រយោជន៍របស់កម្មករនិយោជិតផងដែរ ។ ការអនុវត្តកន្លងមក ពេល ក្រុមហ៊ុនសុំព្យួរកិច្ចសន្យាការងារ អធិការកិច្ចការងារតែងតែចេញលិខិតអនុញ្ញាតិឱ្យ បើសិនជាអធិការកិច្ចការងារ យល់ព្រមឱ្យព្យួរ ។"* (សូមមើលសេចក្តីបង្គាប់ *លេខ ១០៥/០៤-យូណាយធីត អ៊ីធើនីធី ហេតុផលនៃសេចក្តី សម្រេចចំណុច វិវាទទី១ និងលេខ ២៨/០៨-ហ្វាញ ជិស ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទ ទី១ និង២)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា កណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺនៅក្នុងលិខិតឆ្លើយតបរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត របស់លោកនាយកក្រុមហ៊ុន យ៉ុង វ៉ា នេះ បានទទួលស្គាល់ថា ក្រុមហ៊ុនពិតជាបានជួបការលំបាក នៃការធ្លាក់ចុះនៃការបញ្ជាទិញពិតប្រាកដមែន និងបាន អនុញ្ញាតឱ្យក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិតផ្នែកមួយចំនួន នៅ យ៉ុង វ៉ាទី១ និង ទី២ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ផ្នែកមួយចំនួន នៅយ៉ុង វ៉ាទី១ និងទី២ គឺ ក្រុមហ៊ុនអនុវត្តការព្យួរកិច្ចសន្យាកាងារត្រឹមត្រូវច្បាប់ស្តីពីការងារ ។ ហេតុនេះហើយ ក្រុមហ៊ុនមិនជាប់កាតព្វកិច្ច ត្រូវផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ នេះទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ រយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩ ។

THE ARBITRATION COUNCIL

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផល ដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

- បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ រយៈពេល ០២ ខែ ចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹង តិរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ឡូន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈរា**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL